# មេរៀនទី ៥៥៖ ព្រះយេស៊ូវប្រសូត្រហើយ

## លូកា ១៖ ២៦-៣៨, ២៖ ១-២០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/qNqEwkmBjxs

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/ouak-9IBuyQ

**គោលបំណង៖** ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់យើង

**ខគម្ពីរចងចាំ៖ លូកា ២៖១៤** *“ សួស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្តីសុខសាន្តនៅផែនដី នៅកណ្តាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់”។*

**ចំរៀង** ( *យូធូបលីង* )៖

១. យប់ដ៏សុខសាន្ត https://youtu.be/2tmj1KqH-UQ

២. ន៏ពួកទេវច្រៀងបទ https://youtu.be/YdKl42L8W3o

៣. អបអរសាទរ https://youtu.be/K72xD0x_cyg

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត **«តែងតួធ្វើស្តេច»**



សម្ភារៈដែលត្រូវការ៖ ក្រដាសកាត់តុងនិងក្រដាសពណ៌ ហ្វឺត កាវ កន្ត្រៃ ដែកកឹប

១. ចែកកុមារជា២ ឬ ៣ក្រុម

២. សូមពន្យល់កុមារថា ពួកគេត្រូវជ្រើសរើសតំណាងក្រុមម្នាក់ ដើម្បីធ្វើជាស្តេចតំណាងឲ្យក្រុមរបស់ពួកគេ

៣. ឲ្យពួកគេប្រើប្រាស់សម្ភារៈដែលបានឲ្យទៅពួកគេនោះ ដើម្បីមកតុបតែងរយៈពេល ៥ទៅ១០នាទី។

៤. ក្រុមណាដែលតុបតែងបានសមជាងគេក្រុមនោះជាអ្នកឈ្នះ (គ្រូជាអ្នកឲ្យពិន្ទុ)

៥.យើងកំពុងតែតុបតែងខ្លួនជាស្តេច ប៉ុន្តែថ្ងៃនេះយើងនឹងរៀនអំពីស្តេចពិតមួយអង្គ ដែលបានមកសង្គ្រោះយើង។

### ៤. ការណែនាំមេរៀន

តើមានកូនៗណាចាំបានទេថា តើព្រះយេស៊ូវបានយាងមកលើផែនដីដោយរបៀបណា? (**ទ្រង់បានប្រសូត្រមកជាទារក**) តើមុនពេលដែលព្រះយេស៊ូវយាងមកប្រសូតជាមនុស្សតើទ្រង់គង់នៅឯណា? មុនពេលដែលព្រះយេស៊ូវបានប្រសូត្រមកលើផែនដី ព្រះអង្គគឺគង់នៅឯឋានសួគ៌ ដែលនៅជុំវិញនោះសុទ្ធតែជាទេវតា គឺជាអ្នកដែលសរសើរតម្កើង និងថ្វាយសិរីរុងរឿងដល់ព្រះនាមរបស់ទ្រង់។ ទ្រង់គឺជាស្តេចដែលគង់លើបល្ល័ង្ក! តើអ្នកគិតថាហេតុអ្វី បានជាទ្រង់ចាកចេញពីឋានសួគ៌ទៅកើតជាទារក ដែលនឹងពឹងផ្អែកទាំងស្រុងលើមនុស្សផ្សេងទៀតដូច្នេះ?(**ព្រះយេស៊ូវស្រឡាញ់យើងខ្លាំងណាស់ រហូតដល់ថ្នាក់**

ទ្រង់ បានចាកចេញពីស្ថានសួគ៌មកសង្គ្រោះយើង)

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ដំណើររឿងរបស់យើងចាប់ផ្តើមនៅពេលដែលស្តេចនៃដែនដី សេសារ អូស្តូស បានសម្រេចចិត្តថា គាត់ចង់រាប់ចំនួនប្រជាជនទាំងអស់ដែលរស់នៅក្នុងនគររបស់គាត់។ ជំរឿនជាវិធីរាប់មនុស្ស ប៉ុន្តែដើម្បីធ្វើបានអ្នករាល់គ្នាត្រូវធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ។ ម៉ារ៉ានិងយ៉ូសែបមកពីស្រុកបេថ្លេហិម ដូច្នេះពួកគេត្រូវដើរជាច្រើនថ្ងៃដើម្បីត្រឡប់ទៅទីនោះវិញក្នុងការធ្វើជំរឿន។

នៅពេលដែលម៉ារ៉ានិងយ៉ូសែបបានទៅដល់ស្រុកបេថ្លេហិម ទីក្រុងទាំងមូលពោរពេញទៅ ដោយមនុស្សដែលបានធ្វើដំណើរត្រឡប់មកហើយពួកគេទាំងពីរគឺមិនមានផ្ទះសំណាក់ដើម្បីសម្រាកនោះទេ។ នៅពេលដែលពួកគេទៅដល់ជាពេលវេលាដែលបុត្រតូចត្រូវប្រសូត្រ។ តើពួកគេបានទៅទីណា? កន្លែងតែមួយគត់ដែល ពួកគេបានរកឃើញនោះគឺក្រោលសត្វ គឺជាកន្លែងដែលសត្វដេកនិងស៊ីចំណី។ វាមិនមែនជារឿងល្អនោះទេ គឺគួរតែមានមន្ទីរពេទ្យដ៏ស្អាត ហើយមានគ្រូពេទ្យល្អៗចាំជួយមើលថែគាត់។ ស្តាប់ទៅ តើវាសាកសមដែរឬទេ ដែលស្តេចត្រូវបានប្រសូត្រនៅកន្លែងដូច្នេះនោះ?

មនុស្សគ្រប់គ្រប់គ្នាដែលបានឮអំពីការប្រសូត្ររបស់ព្រះយេស៊ូវគឺជាដំណឹងល្អ។ ព្រះបានសន្យាថានឹងប្រទានព្រះមេស្ស៊ីជាម្នាក់ដែលជួយឲ្យយើងរួចពីអំពើបាប។ ព្រះយេស៊ូវជាព្រះមេស្ស៊ី ដែលយើងទទឹងរងចាំជាយូរមកហើយ! ទ្រង់មានជីវិតរស់នៅដ៏ល្អបំផុតមិនមានអំពើបាប ហើយបានលះបង់ព្រះជន្ម ដើម្បីសុគតលើឈើឆ្កាងលោះបាបយើង។ ហើយឥឡូវនេះ នៅពេលដែលនរណាម្នាក់ ដាក់សេចក្តីជំនឿរបស់ពួកគេលើព្រះយេស៊ូវ នោះអំពើបាបរបស់ពួកគេទាំងអស់ត្រូវបានសម្អាត ហើយពួកគេនឹងមានទំនាក់ទំនងជាមួយព្រះ! ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់យើង! ហើយសូម្បីតែឥឡូវនេះ ព្រះយេស៊ូវ កំពុងតែគ្រងរាជលើបល្ល័ង្ករបស់ទ្រង់ ពីព្រោះព្រះអង្គជាស្តេចរបស់យើង! ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់យើង!

យើងអរព្រះគុណដល់ព្រះវរបិតាដែលបានប្រទានព្រះយេស៊ូវគ្រីស្ទជាអង្គសង្គ្រោះរបស់យើង! ដោយសារតែយើងទទួលបានការអត់ទោសពីព្រះ យើងក៏អត់ទោសដល់អ្នកដែលធ្វើខុសលើយើងផងដែរ។ គឺមានន័យថា យើងមិនចាំបាច់ស្ពាយភាពល្វីងជូរចត់ និងការខឹងស្អប់ទៅកាន់អ្នកដទៃនោះទេ! យើងអាចស្រលាញ់ពួកគេបាន ដោយសារព្រះជាម្ចាស់បានស្រលាញ់យើងជាមុន តាមរយៈការចាត់ព្រះយេស៊ូវគ្រីស្ទឲ្យមកធ្វើជាអង្គសង្គ្រោះរបស់យើង!

## ៦. សំនួរពិភាក្សា

១. តើភូមិដែលព្រះយេស៊ូវប្រសូត្រមានឈ្មោះអ្វី? *( បេថ្លេហិម)*

២. តើក្រោលសត្វជាកន្លែងសំរាប់ដាក់អ្វី?*( ជាកន្លែងដែលសត្វដេកនិងស៊ីចំណី)*

៣. តើប្អូនៗកើតនៅទីកន្លែងណា?*(ទុកអោយក្មេងឆ្លើយ)*

៤. តើនរណាដែលបានកើតនៅក្នុងក្រោលសត្វ?*(ព្រះយេស៊ូវ)*

៥. តើព្រះយេស៊ូវគឺជានរណា? *(ទ្រង់គឺជាព្រះអង្គសង្គ្រោះ)*

## ៧. ល្បែងកំសាន្ត «ស្តេចដ៏ល្អ»

សម្ភារៈដែលត្រូវការ៖ អំបោស ២ និងដុំសំឡីតូចៗ(សំឡីផ្លែគក៏បាន)

១.ចែកកុមារជាពីរក្រុមហើយឲ្យពួកគេឈរនៅជ្រុងផ្ទុយ ពីគ្នានៃថ្នាក់រៀន

២. ឲ្យអំបោសមួយទៅក្រុមនីមួយៗ



៣. ពង្រាយដុំសំឡីតូចៗនោះឲ្យពេញថ្នាក់រៀន

៤.សូមពន្យល់កុមារថា ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះ ប៉ុន្តែទ្រង់មិនដែលចាត់ទុកយើងជាអ្នកបម្រើឡើយ។ ព្រះអង្គមើលថែយើងដូចជាចៀម ហើយដឹកនាំយើងទៅកាន់កន្លែងដែលមានសុវត្ថិភាព។

៥. កុមារដើរតួជាស្តេចដ៏ល្អ ហើយដុំសំឡីគឺជាកូនចៀម។

៦.កុមារត្រូវប្តូរវេនគ្នាក្នុងការបោសសម្អាតដុំសំឡី (កូនចៀម) ឲ្យច្រើនតាមដែលអាចធ្វើទៅបានទៅទុកនៅកន្លែងណាមួយនៃបន្ទប់រៀន(កន្លែងណាក៏បាន)។

៧. យើងក៏ត្រូវព្យាយាមបញ្ឈប់ក្រុមម្ខាងទៀត មិនឲ្យប្រមូលដុំសំឡីបានផងដែរ។

៨.កុមារម្នាក់មានពេល ១០វិនាទី បន្ទាប់ពី១០ វិនាទីក្រោយមក ឲ្យកុមារម្នាក់ទៀតទៅបោសប្រមូលដុំសំឡីម្តង។

៩. បន្ទាប់ពីលេងល្បែងចប់៖

ក. តើវាងាយស្រួលដែរឬទេក្នុងការបោសប្រមូលដុំសំឡី(កូនចៀម)?

ខ.ត្រូវចាំថា ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់យើង ហើយគ្មានអ្វីដែលពិបាកសម្រាប់ទ្រង់ឡើយ។ ត្រូវទុកចិត្តលើទ្រង់នោះព្រះអង្គនិងមើលថែយើង!

### ៨. ខគម្ពីរចងចាំ

**លូកា ២៖១៤** *"សួស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្តីសុខសាន្តនៅផែនដី នៅកណ្តាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់"*។

### ៩. ហត្ថកម្ម «មកុដសម្រាប់ស្តេច!»

សម្ភារៈដែលត្រូវការ៖ ដុំសំឡី ខ្មៅដៃពណ៌ ការ សូមបោះពុម្ពមកុដ (មើលនៅទំព័រខាងក្រោម)



១. សូមឲ្យមកុដដែលបានបោះពុម្ពរួចទៅកុមារគ្រប់ៗគ្នា

២. ពួកគេអាចតុបតែងដោយការផាត់ពណ៌ និងបិទដុំសំឡីក៏បាន។

៣. សូមពន្យល់ទៅកុមារថា នេះគឺជាមកុដសម្រាប់ ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់យើង។

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
វាគឺមានសារៈសំខាន់ណាស់ដែលត្រូវចងចាំថា ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់យើង។ ទ្រង់មិនត្រឹមតែយាងមកសុគត ដើម្បីសង្គ្រោះយើងពីអំពើបាបប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏យាងមកដើម្បីធ្វើជាស្តេចរបស់យើងផងដែរ។ ព្រះយេស៊ូវគឺជាស្តេចដែលពេញទៅដោយសេចក្តីមេត្តាករុណា និងពោរពេញទៅដោយសេចក្តីស្រលាញ់សម្រាប់យើង។ ទូលសូមព្រះឲ្យប្រទានសេចក្តីជំនឿ និងប្រាជ្ញាសម្រាប់អ្នកនៅថ្ងៃនេះ ក្នុងការចែកចាយអំពីព្រះយេស៊ូវគ្រីស្ទជាអង្គសង្គ្រោះរបស់យើង។

